ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ប្រក

**ប្រកាសអន្តរក្រសួង**

**ស្តីពី**

**ការបង្កើតរង្វាន់ទេយ្យបុរេប្រទាន**

**នៅមូលនិធិជនពិការ**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពី លក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧

- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិជនពិការ
- បានឃើញអនុក្រឹតលេខ ២៩១ អនក្រ.តត ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃមូលនិធិជនពិការ
- បានឃើញអនុក្រឹតលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨១អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៥៩៨ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការបង្កើតបន្ថែមគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៨៩៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបង្កើតបន្ថែមគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៩១៤ សហវ.ប្រក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យរបស់មូលនិធិជនពិការ
- បានឃើញប្រកាសលេខ ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា(មូលនិធិជនពិការ)

**សម្រេច**

**ប្រការ១.–**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក៦០ "ការទិញ" ជំពូក៦១ "សេវាកម្ម" ជំពូក៦២ "អត្ថប្រយោជន៍សង្គម" និងជំពូក៦៤ "បន្ទុកបុគ្គលិក" នៅមូលនិធិជនពិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីនីតិវិធី

ចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ២.—**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.—**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន ប្រធានអង្គភាពទទួលបន្ទុករដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងនាយកមូលនិធិជនពិការ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**វង សូត**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មូលនិធិជនពិការ

## តារាងឧបសម្ព័ន្ធស្នើសុំបុរេប្រទានថវិកាកម្មវិធី
## របស់មូលនិធិជនពិការ ឆ្នាំ២០១៧

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧ | ឥណទានដែលស្នើបើក | ឥណទានស្នើសុំបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទានមធ្យមប្រចាំត្រីមាសស្នើសុំបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដង | ៦=៣/២ |
| | | | **សរុបរួម** | 6,228,900,000 | 1,745,346,100 | 1,036,384,800 | 708,963,300 | 259,096,200 | 59% |
| 60 | | | **ការទិញ** | 3,813,782,700 | 532,963,800 | 171,000,000 | 361,963,800 | 42,750,000 | 32% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 370,500,000 | | | | | |
| | | 60011 | សម្ភារៈផ្គត់ផ្គង់ សំអាត និងអនាម័យ | 211,500,000 | | | | | |
| | | 60015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | 159,000,000 | | | | | |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 301,969,500 | 301,969,500 | 36,000,000 | 265,969,500 | 9,000,000 | 12% |
| | | 60021 | សម្ភារៈការិយាល័យ និងការបោះពុម្ព | 301,969,500 | 301,969,500 | 36,000,000 | 265,969,500 | 9,000,000 | 12% |
| | 6004 | | សំលៀកបំពាក់ និងការតុបតែង | 64,115,500 | | | | | |
| | | 60042 | សំលៀកបំពាក់ការពារសុវត្ថិភាព | 64,115,500 | | | | | |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 221,973,000 | 36,000,000 | 36,000,000 | - | 9,000,000 | 100% |
| | | 60051 | សម្ភារៈ និងបរិក្ខារបច្ចេកទេស | 185,973,000 | | | | | |
| | | 60052 | សង្ហារឹម | - | | | | | |
| | | 60053 | សម្ភារៈប្រើប្រាស់ | 36,000,000 | 36,000,000 | 36,000,000 | - | 9,000,000 | 100% |
| | 6006 | | ថាមពល និងទឹក | 194,994,300 | 194,994,300 | 99,000,000 | 95,994,300 | 24,750,000 | 51% |
| | | 60061 | អគ្គិសនី | 173,251,000 | 173,251,000 | 86,000,000 | 87,251,000 | 21,500,000 | 50% |
| | | 60062 | ទឹក | 21,743,300 | 21,743,300 | 13,000,000 | 8,743,300 | 3,250,000 | 60% |
| | 6007 | | សម្ភារបរិក្ខារថែទាំសុខភាព | 2,660,230,400 | - | - | - | - | |
| | | 60072 | សម្ភារៈបរិក្ខារពេទ្យ( ឧបករណ៍ សម្ភារបរិក្ខារពេទ្យ និងបរិក្ខារព្យាបាលដោយចលនា ) | 478,067,800 | | | - | - | |
| | | 60078 | សម្ភារៈបរិក្ខារថែទាំសុខភាពផ្សេងៗ( ឧបករណ៍ សម្ភារ និងវត្ថុធាតុដើមផលិតអវយវៈសិប្បនិម្មិត និងរណប ) | 2,182,162,600 | | | - | - | |
| 61 | | | **សេវាកម្ម** | 958,755,300 | 734,014,800 | 529,704,800 | 204,310,000 | 132,426,200 | 72% |
| | 6101 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស | 14,700,000 | 14,700,000 | 8,000,000 | 6,700,000 | 2,000,000 | 54% |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 13,300,000 | 13,300,000 | 8,000,000 | 5,300,000 | 2,000,000 | 60% |
| | 6105 | | ការថែទាំ និងជួសជុល | 299,500,000 | 133,480,000 | 133,480,000 | - | 33,370,000 | 100% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 113,900,000 | | | - | - | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61053 | ការថែទាំ និងជួសជុលផ្លូវ ថ្នល់ ស្ពាន និងលូ | 52,120,000 | | | - | - | |
| | | 61054 | ការថែទាំ បណ្តាញផ្សេងៗ | 21,480,000 | 21,480,000 | 21,480,000 | - | 5,370,000 | 100% |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | 39,000,000 | 39,000,000 | 39,000,000 | - | 9,750,000 | 100% |
| | | 61057 | ការថែទាំ និងជួសជុលសំភារៈឧបករណ៍បច្ចេកទេស(ផ្នែករោងជាង) | 41,000,000 | 41,000,000 | 41,000,000 | - | 10,250,000 | 100% |
| | | 61058 | ការថែទាំ និងជួសជុលផ្សេងៗ(សម្ភារៈឧបករណ៍ការិយាល័យ,ព័ត៌មាន) | 32,000,000 | 32,000,000 | 32,000,000 | - | 8,000,000 | 100% |
| | 6110 | | **ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ** | 254,356,000 | 224,856,000 | 137,056,000 | 87,800,000 | 34,264,000 | 61% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 26,536,000 | 26,536,000 | 26,536,000 | - | 6,634,000 | 100% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 5,520,000 | 5,520,000 | 5,520,000 | - | 1,380,000 | 100% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 101,300,000 | 101,300,000 | 60,000,000 | 41,300,000 | 15,000,000 | 59% |
| | | 61104 | សោហ៊ុយពិធីបុណ្យ | 29,500,000 | | | - | - | |
| | | 61107 | ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 91,500,000 | 91,500,000 | 45,000,000 | 46,500,000 | 11,250,000 | 49% |
| | 6111 | | **ចំណាយលើការជាវសារព័ត៌មាន និងឯកសារ** | 1,768,800 | 1,768,800 | 1,768,800 | - | 442,200 | 100% |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 1,768,800 | 1,768,800 | 1,768,800 | - | 442,200 | 100% |
| | 6112 | | **ចំណាយខ្ទាត់សោហ៊ុយក្នុងប្រទេស** | 320,566,000 | 320,566,000 | 225,000,000 | 95,566,000 | 56,250,000 | 70% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន(ធ្វើដំណើរ) | 55,794,000 | 55,794,000 | 39,000,000 | 16,794,000 | 9,750,000 | 70% |
| | | 61122 | សោហ៊ុយបេសកកម្ម | 37,204,000 | 37,204,000 | 26,000,000 | 11,204,000 | 6,500,000 | 70% |
| | | 61123 | សោហ៊ុយស្នាក់នៅ(និងហូបចុក) | 227,568,000 | 227,568,000 | 160,000,000 | 67,568,000 | 40,000,000 | 70% |
| | 6113 | | **ចំណាយខ្ទាត់សោហ៊ុយក្រៅប្រទេស** | 22,128,000 | 22,128,000 | 15,400,000 | 6,728,000 | 3,850,000 | 70% |
| | | 61131 | សោហ៊ុយធ្វើដំណើរ | 12,295,000 | 12,295,000 | 8,600,000 | 3,695,000 | 2,150,000 | 70% |
| | | 61132 | សោហ៊ុយបេសកកម្ម | 5,200,000 | 5,200,000 | 3,600,000 | 1,600,000 | 900,000 | 69% |
| | | 61133 | សោហ៊ុយស្នាក់នៅ(និងហូបចុក) | 4,633,000 | 4,633,000 | 3,200,000 | 1,433,000 | 800,000 | 69% |
| | 6114 | | **សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍** | 32,436,500 | 3,216,000 | 1,000,000 | 2,216,000 | 250,000 | 31% |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 3,216,000 | 3,216,000 | 1,000,000 | 2,216,000 | 250,000 | 31% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 29,220,500 | | | - | - | |
| 64 | | | **បន្ទុកបុគ្គលិក** | 1,069,192,500 | 91,200,000 | 54,720,000 | 36,480,000 | 13,680,000 | 60% |
| | 6401 | | **លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ** | 91,200,000 | 91,200,000 | 54,720,000 | 36,480,000 | 13,680,000 | 60% |
| | | 64016 | លាភការក្រុមប្រឹក្សាភិបាល (ពេលប្រជុំក្រុមប្រឹក្សាភិបាល) | 91,200,000 | 91,200,000 | 54,720,000 | 36,480,000 | 13,680,000 | 60% |
| | 6403 | | **វង្វាន់ និងប្រាក់បំណាច់ផ្សេងៗ(បុគ្គលិកក្របខ័ណ្ឌ)** | 606,720,000 | - | | | | |
| | | 64036 | ប្រាក់បំណាច់ផ្សេងៗ(ប្រាក់កម្រៃលើកទឹកចិត្ត) | 606,720,000 | | | | | |
| | 6404 | | **លាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ** | 365,520,000 | - | | | | |
| | | 64041 | បៀវត្សមូលដ្ឋានបុគ្គលិកកិច្ចសន្យា | 365,520,000 | | | | | |
| | 6405 | | **ប្រាក់វិភាជន៍សង្គម** | 5,752,500 | - | | | | |
| | | 64056 | គ្រោះថ្នាក់ក្នុងការងារ និងទុព្វលភាព | 5,752,500 | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 62 | | | អត្ថប្រយោជន៍សង្គម | 387,169,500 | 387,169,500 | 280,960,000 | 106,209,500 | 70,240,000 | 73% |
| | 6202 | | ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 48,000,000 | 48,000,000 | 48,000,000 | - | 12,000,000 | 100% |
| | | 62022 | ឱសថ | 48,000,000 | 48,000,000 | 48,000,000 | - | 12,000,000 | 100% |
| | 6203 | | ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ | 339,169,500 | 339,169,500 | 232,960,000 | 106,209,500 | 58,240,000 | 69% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០៧ ខែឧសភ ឆ្នាំ២០១៧
អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ

បណ្ឌិត វង្ស ប៊ុនឥន្ទ្រាវុធ

បានឃើញ និងពិនិត្យត្រឹមត្រូវ
គណនេយ្យករ

ឃិន សុផល

ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦
គណនេយ្យករបុរេប្រទាន

គុន ដាលី

បានឃើញ និងឯកភាព
ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៧
[illegible] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ពន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧
មូលនិធិជនពិការ

ជួន រតនៈ